ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
លេខ: ០០៦ ស.ស.រ ក.ជ.អ.ច.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ៥៤ សសរ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- យោងស្មារតីកិច្ចប្រជុំលើកទី១នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ប.អ.** និងជាភាសាអង់គ្លេសថា Climate Change Technical Working Group (CCTWG) ដើម្បីសម្របសម្រួលនិងគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(**ក.ជ.អ.ច.**) ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

**ក.ប.ប.អ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម ជួប ប៉ារីស៍ | អគ្គលេខាធិការរង<br>អគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** | ប្រធាន |
| ២.លោក ស៊ុំ ធី | ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ<br>អគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** | អនុប្រធានទី១ |
| ៣.លោក ថៃ ចន្ថា | ប្រធាននាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ<br>ក្រសួងបរិស្ថាន | អនុប្រធានទី២ |
| ៤.ឯកឧត្តម សុទ្ធ គឹមកុលមុនី | ទីប្រឹក្សា គ.ជ.គ.ម. និងជាអនុប្រធាននាយកដ្ឋានត្រៀមរៀបចំនិងបណ្ដុះបណ្ដាល<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ៥.លោក តូច ច័ន្ទក្រឹស្នា | អគ្គនាយករង អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦.លោក ប៊ូ ចន្ទសិរី | អគ្គនាយករង អគ្គនាយកដ្ឋានទេសចរណ៍<br>ក្រសួងទេសចរណ៍ | សមាជិក |
| ៧.លោក វ៉ែន គៀហាក់ | អគ្គនាយករង អគ្គនាយកដ្ឋានឧស្សាហកម្ម<br>ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨.លោក ជីវ សុភារិទ្ធ | ប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង<br>ក្រសួងបរិស្ថាន | សមាជិក |
| ៩.លោក សាន វណ្ណរិទ្ធ | ប្រធាននាយកដ្ឋានផែនការវិនិយោគ<br>ក្រសួងផែនការ | សមាជិក |
| ១០.លោក អោ សៀម | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា<br>ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១.លោក កុល ហេរ៉ូ | ប្រធាននាយកដ្ឋានការពារសុខភាព<br>ក្រសួងសុខាភិបាល | សមាជិក |

| | | |
|---|---|---|
| ១២.លោក ច្រៀង ផល័ក្ខ | ប្រធាននាយកដ្ឋានផែនការ<br>ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៣.លោក ជូ ហេង | ប្រធាននាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤.លោក សេង សុចិន្តា | ប្រធាននាយកដ្ឋានវាយតម្លៃខាងបរិស្ថាន<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥.លោក សុខ ហេង | ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦.លោក អំ កិរម្យ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៧.លោក ឆេង ផែន | អនុប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៨.លោក នូវ បូរី | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា<br>ក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៩.លោក ថាច់ សុវណ្ណា | អនុប្រធាននាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធានទឹក<br>ក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ២០.លោក ស៊ីយ៉ុន សុចិត្រ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍<br>ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២១.លោក ដោក ដូម៉ា | អនុប្រធាននាយកដ្ឋានស្រាវជ្រាវនិងបទប្បញ្ញត្តិ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២២.លោក កុល ផាន់ណា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងព័ត៌មាន | សមាជិក |
| ២៣.លោក សោម ពិសិដ្ឋ | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងកិច្ចការនារី | សមាជិក |
| ២៤.លោក ឈុន ប៊ុនណារ៉ា | អនុប្រធានអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី<br>លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ<br>តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | សមាជិក |
| ២៥.លោកស្រី ឃ្លោក វិចិត្ររង្សី | អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ<br>អគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** | សមាជិកអចិន្ត្រៃយ៍។ |

**ប្រការ៣ _**

សមាជិក **ក.ប.ប.អ.** មានភារកិច្ចដូចខាងក្រោម៖

- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬតាមវិស័យ ដែលកំពុងរៀបចំឬកែសម្រួល
- ផ្តល់ធាតុចូលសំខាន់ៗដល់ការរៀបចំផលិតផលចំណេះដឹង សម្ភារៈឧបទ្ទេស និងចែករំលែកមេរៀនបទពិសោធន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យរបស់ខ្លួន និងចូលរួមក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពត្រួតពិនិត្យនិងវាយតម្លៃក្នុងវិស័យរបស់ខ្លួន
- ចូលរួមពិនិត្យនិងពង្រឹងក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុក្នុងវិស័យរបស់ខ្លួន
- វិភាគនិងផ្សព្វផ្សាយលទ្ធផលនិងអនុសាសន៍ ពីការត្រួតពិនិត្យនិងវាយតម្លៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិនិងថ្នាក់វិស័យ សំដៅពង្រីកវិសាលភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ចូលរួមរៀបចំរបាយការណ៍ប្រចាំឆ្នាំ អំពីសូចនាករទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចមាននៅក្នុងក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃនៅថ្នាក់ជាតិនិងថ្នាក់វិស័យ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ចូលរួមក្នុងការរៀបចំរបាយការណ៍ជាទៀងទាត់ អំពីការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្ត្រនិងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ
- សហការនិងចែករំលែកព័ត៌មាននិងទិន្នន័យ ដើម្បីរៀបចំរបាយការណ៍ជាតិ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរបាយការណ៍ផ្សេងទៀត តាមតម្រូវការរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) និងដើម្បីជាព័ត៌មានដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ពិនិត្យនិងផ្តល់អនុសាសន៍ លើការរៀបចំរបាយការណ៍ជាតិនានា រាប់បញ្ចូលទាំងរបាយការណ៍សម្រាប់UNFCCC
- ចូលរួមវាយតម្លៃផ្នែកបច្ចេកទេសនៃគម្រោងហិរញ្ញវត្ថុអាកាសធាតុតាមការអញ្ជើញរបស់ប្រធាន
- ចូលរួមក្នុងការកៀរគរធនធានសម្រាប់ការឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការពិភាក្សាគោលនយោបាយនិងការសម្របសម្រួលជាមួយម្ចាស់ជំនួយ វិស័យឯកជន និងអង្គការសង្គមស៊ីវិលយ៉ាងទៀងទាត់

- ផ្តល់ព័ត៌មានអំពីការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ និងកំណត់អត្តសញ្ញាណតម្រូវការនិងកាលានុវត្តភាពសម្រាប់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ
- ចូលរួមនិងសម្របសម្រួលដំណើរការវាយតម្លៃសមត្ថភាពនិងការកសាងសមត្ថភាព ក្នុងវិស័យពាក់ព័ន្ធ ដើម្បីពង្រឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ
- ចូលរួមកំណត់តម្រូវការនិងកាលានុវត្តភាពនៃបន្ទេរនិងអភិវឌ្ឍន៍បច្ចេកវិទ្យា ការអនុវត្តសាកល្បងបច្ចេកវិទ្យានវានុវត្ត និងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដើម្បីជួយដល់ការពង្រីកការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ចូលរួមនិងសម្របសម្រួលសកម្មភាពលើកកម្ពស់ការយល់ដឹងនិងការផ្សព្វផ្សាយអំពីការឆ្លើយតបជាតិទៅនឹងការប្រែប្រួលអាកាសធាតុដល់សាធារណជន ដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងៗ
- ចូលរួមកំណត់អាទិភាពនិងរៀបចំផែនការការងារសម្រាប់ **ក.ប.ប.អ.**
- ដើរតួជាជនបង្គោលបច្ចេកទេសតាមស្ថាប័នរបស់ខ្លួន ដើម្បីសម្របសម្រួលដល់ការពិនិត្យ ការចងក្រង និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធី សំដៅពង្រឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលនិងរាយការណ៍ជាទៀងទាត់ជូនសមាជិក **ក.ជ.អ.ច.** តាមស្ថាប័នរបស់ខ្លួន។

**ប្រការ៤ ._**

**ក.ប.ប.អ.** ត្រូវរៀបចំប្រជុំជាទៀងទាត់ ចំនួន ២ដង ក្នុង១ឆ្នាំ ដើម្បីពិនិត្យពីវឌ្ឍនភាពនិងរៀបចំផែនការ។ ប្រធានក.ប.ប.អ. អាចកោះប្រជុំបន្ថែមតាមការចាំបាច់។ សមាជិក **ក.ប.ប.អ.** ក៏ត្រូវចូលរួមក្នុងក្រុមការងារពិសេសដែលបង្កើតឡើងដោយ **ក.ប.ប.អ.** តាមការស្នើសុំរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់សិទ្ធិពីប្រធាន។ សមាជិក **ក.ប.ប.អ.** អាចផ្តល់សិទ្ធទៅអ្នកជំនួសរបស់ខ្លួនពេលអវត្តមាន ដោយជូនដំណឹងទៅប្រធានជាមុន។

តំណាងអង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ អាចចូលរួមប្រជុំជាអ្នកសង្កេតការណ៍ តាមការអញ្ជើញរបស់ប្រធានឬអនុប្រធាន។ សមាជិក **ក.ប.ប.អ.** មានសិទ្ធិស្នើទៅប្រធាន ដើម្បីឱ្យតំណាងអង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ បានចូលរួមប្រជុំជាអ្នកសង្កេតការណ៍។

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** ត្រូវដើរតួនាទីជាលេខាធិការដ្ឋាននៃ **ក.ប.ប.អ.** ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

ក្រសួងស្ថាប័នពាក់ព័ន្ធ សមាជិក **ក.ជ.អ.ច.** ដែលមានសមាជិកក្នុងស្ថាប័នរបស់ខ្លួនដូចមានចែងក្នុងប្រការ២ អគ្គលេខាធិការ ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងប្រធាននាយកដ្ឋានផែនការ រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៦ ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ